ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៥៣០០...សហវ...

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១៤

សូមគោរពជូន
ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

កម្មវត្ថុ : ករណីសំណើសុំថវិកាបដិភាគពីរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយមូលនិធិសកលឆ្នាំ ២០១៥-២០១៧ តាមគំរូហិរញ្ញប្បទានថ្មីរបស់មូលនិធិសកល។

យោង : លិខិតលេខ ៥៧៩ អជបជអ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ របស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាជ្រាបថា ថវិកាបដិភាគដែលមូលនិធិសកល តម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជាចូលរួមចំណែកមួយភាគ សម្រាប់ទិញឱសថប្រឆាំងមេរោគអេដស៍ គឺរាជរដ្ឋាភិបាលអាចចូលរួមចំណែកតាមការស្នើសុំបាន ដើម្បីឱ្យស្របតាមលក្ខខណ្ឌតម្រូវនៃគំរូហិរញ្ញប្បទានថ្មីរបស់មូលនិធិនេះ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងស្នើឱ្យក្រសួងសុខាភិបាល ចោះក្រវិលថវិកាស្មើប្រមាណ១,០ លានដុល្លារអាមេរិក សម្រាប់ទិញឱសថប្រឆាំងមេរោគអេដស៍ នៅក្នុងឆ្នាំ២០១៥ ព្រោះក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ថវិកាចំនួន៣០៣ ២១៨,២លានរៀល ត្រូវបានគ្រោងជូនក្រសួងសុខាភិបាលសម្រាប់ទិញឱសថ ហើយក្នុងទំហំទឹកប្រាក់នេះ ក្រសួងសុខាភិបាល អាចចោះក្រវិលថវិកាទុកក្នុងទំហំទឹកប្រាក់ប្រមាណ១,០លានដុល្លារអាមេរិកបាន។

ម្យ៉ាងទៀត ចំពោះកាតព្វកិច្ចបដិភាគ ដែលគ្រោងអាចមានចំនួនថវិកាប្រមាណ១,២លានដុល្លារអាមេរិកសម្រាប់ឆ្នាំ២០១៦ និងប្រមាណ១,៥លានដុល្លារអាមេរិកសម្រាប់ឆ្នាំ២០១៧ ក្រសួងសុខាភិបាល

ផ្ទះលេខ ៥២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

អាចគ្រោងថវិកាត្រៀមបម្រុងសម្រាប់ទិញឱសថប្រឆាំងមេរោគអេដស៍នេះ នៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបជាព័ត៌មាន តាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

រដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រី

បណ្ឌិត. អ៊ុន

ចំលងជូន

- ក្រសួងសុខាភិបាល